នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសស |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jun-2013, 14:01
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំការពិចារណាឡើងវិញចំពោះសេចក្ដីសម្រេច ទាក់ទងនឹងការទទួលយកសារទូរលេខតាមផ្លូវការទូតរបស់សហរដ្ឋអាមេរិកដែលទើបរកបានថ្មីៗ**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

ជនជាប់ចោទ
នួន ជា
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អារុណ
លោក Victor Koppe
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Jacques VERGÈS
លោក Arthur VERCKEN

# I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១. សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញ ចំពោះ "សេចក្តីសម្រេចរបស់ខ្លួន លើសំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងស្តីពីសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក" ដែលបានចេញនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ ("សេចក្តីសម្រេចច្រានចោល")[1] ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សារទូរលេខតាមផ្លូវការទូតរបស់សហរដ្ឋអាមេរិកដែលបានផ្សព្វផ្សាយជាសាធារណៈដែលទើបរកឃើញថ្មីៗនេះ ("សារទូរលេខ") មិនអាចទទួលយកបាន អនុលោមតាមវិធាន៨៧(៣)(ក) និង (ខ) នៃវិធានផ្ទៃក្នុង។ នៅក្នុងសេចក្តីសម្រេចច្រានចោល អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា គេមានការពេញចិត្តដែលសហព្រះរាជអាជ្ញាបាន "បំពេញនូវការព្យាយាមសមហេតុផលក្នុងការរកឃើញ និងបង្ហាញភ័ស្តុតាងថ្មីនេះនៅពេលដែល WikiLeaks បានបង្កើតឲ្យមានមូលដ្ឋានទិន្នន័យដែលអាចស្រាវជ្រាវបានកាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣"[2]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានកត់សំគាល់ថា ខ្លួនមិនអាច "ធ្វើការសន្និដ្ឋានជាចុងក្រោយថា សម្ភារៈដែលទទួលបានពីគេហទំព័ររបស់ WikiLeaks នេះពិតជាមានយថាភូតពិតប្រាកដ" និងបានសម្រេចថា ការព្យាយាមណាមួយដើម្បីទទួលបានសារទូរលេខពីប្រភពផ្លូវការនានា នឹងមិនអាចបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣)(ខ) ឡើយដែលវិធាននេះតម្រូវថា ភាពអាចរកបាននៃឯកសារ "ត្រូវស្ថិតក្នុងពេលវេលាសមស្រប"[3]។ អង្គជំនុំជម្រះក៏បានរកឃើញថាសារទូរលេខទាំងនេះ "មានលក្ខណៈច្រំដែល" ដោយសារតែលក្ខណៈបមាណីយកម្មរបស់វា និងដោយសារការ

---

[1] **E282/2** "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងស្តីពីសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក (E282 និង E282/1; E290 និង E290/1)", ១៣ មិថុនា ២០១៣, កថាខណ្ឌទី៧-៨ ("សេចក្តីសម្រេចច្រានចោល")។

[2] សេចក្តីសម្រេចច្រានចោល, កថាខណ្ឌទី៥។

[3] សេចក្តីសម្រេចច្រានចោល, កថាខណ្ឌទី៧។

ពិតដែលថា សារទូរលេខមាន "ភ័ស្តុតាងសារតា... ពាក់ព័ន្ធនឹងកាលៈទេសៈទាំងឡាយដែលកើតមុននៅកម្ពុជាក្នុងចន្លោះឆ្នាំ១៩៧៣ និង១៩៧៥"[4]។

២. សហព្រះរាជអាជ្ញាសូមស្នើឲ្យពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចច្រានចោល ស្របតាម៖

ក. ព័ត៌មានថ្មីៗដែលអាចរកបានទាក់ទងនឹងប្រភពជាយថាភូត និងភាពអាចរកបានភ្លាមៗនៃសារទូរលេខទាំងនេះ ដែលបានទាញយកពីប្រភពមូលដ្ឋានទិន្និន័យអនឡាញផ្លូវការដែលបានរក្សាទុកដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ("ស.រ.អា") និង

ខ. ការពិតដែលថា ការមិនទទួលយកសារទូរលេខដែលមានយថាភូតពិតប្រាកដពេលនេះ នឹងជាការផ្ទុយទៅនឹងផលប្រយោជន៍នៃយុត្តិធម៌ ដោយហេតុថាវានឹងច្រានចោលពីការពិចារណាចំពោះភាពជាប់ពាក់ព័ន្ធ និងតម្លៃភវនីយភាពនៃឯកសារចំពោះបញ្ហាគន្លឹះនានានៅក្នុងរឿងក្ដីនេះ។ ដូចបានបង្ហាញបន្ថែមនៅក្នុងវាក្យខណ្ឌ II ខាងក្រោម សារទូរលេខពិតជាមិនបានផ្ដល់នូវព័ត៌មានដែលមានភាពច្រំដែលឡើយ ប៉ុន្តែជាព័ត៌មានថ្មី និងជាព័ត៌មានបន្ថែមទៅលើភ័ស្តុតាងដែលបានទទួលយករួចហើយរហូតមក។

## II. ការសាកល្បងផ្លូវច្បាប់ និងសំណើឲ្យមានការពិចារណាឡើងវិញ

### *ក. មូលដ្ឋានសម្រាប់សំណើឲ្យមានការពិចារណាឡើងវិញ*

៣. អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា "ពាក្យសុំឲ្យមានការពិចារណាឡើងវិញអាចទទួលជោគជ័យទៅបានអាស្រ័យមូលដ្ឋានស្របច្បាប់របស់វា ដើម្បីឲ្យអង្គបុរេជំនុំជម្រះពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចពីមុនណាមួយរបស់ខ្លួន"[5]។ លើសពីនេះ ដោយបានលើកយោងករណីយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា អង្គបុរេជំនុំជម្រះបានរកឃើញថា ខ្លួនមានអំណាចជាប់មកជាមួយដើម្បីពិចារណាឡើងវិញចំពោះសេចក្ដីមួយនៃសេចក្ដីសម្រេចពីមុនៗរបស់ខ្លួន នៅពេលណាការ

---

[4] សេចក្ដីសម្រេចច្រានចោល, កថាខណ្ឌទី៨។

[5] **C22/I/41** សេចក្ដីសម្រេចទទួលយកសេចក្ដីសង្ខេបជាទូទៅរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, ២៤ មិថុនា ២០០៨ (អង្គបុរេជំនុំជម្រះ) ត្រង់កថាខណ្ឌ៣, ២៥។ **C22/I/68** សេចក្ដីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង, ២៨ សីហា ២០០៨, ត្រង់កថាខណ្ឌទី២៥។ **D99/3/41** សេចក្ដីសម្រេចលើពាក្យសុំការពិចារណាឡើងវិញរបស់ អៀង សារី ចំពោះសេចក្ដីសម្រេចស្ដីពីការដាក់ពាក្យសុំនៅក្នុងសំណុំរឿង "ខុច", ៣ ធ្នូ ២០០៨, ត្រង់កថាខណ្ឌទី៦។

ផ្លាស់ប្តូរនៃកាលៈទេសៈអនុញ្ញាត នៅពេលដែលតុលាការរកឃើញថា សេចក្តីសម្រេចពីមុនរបស់ខ្លួនមានកំហុស ឬនៅពេលណាសេចក្តីសម្រេចនោះបង្ករឲ្យមានភាពអយុត្តិធម៌[6]។

៤. ការផ្លាស់ប្តូរនៃកាលៈទេសៈដែលពាក់ព័ន្ធនេះ គឺការរកឃើញនូវមូលដ្ឋានទិន្នន័យផ្លូវការមួយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលតាមរយៈមូលដ្ឋានទិន្នន័យនេះ សារទូរលេខទាំងឡាយត្រូវទាញយកក្នុងទម្រង់ និងខ្លឹមសារដូចគ្នានឹងឯកសារនានាដែលបានដាក់ជូនទៅជាមួយនឹង "សំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងសារទូរលេខតាមផ្លូវការទូតរបស់សហរដ្ឋអាមេរិកដែលរកបានថ្មីៗ" ("សំណើដើម")។ នៅពេលដាក់សំណើដើមនេះ គឺដាក់ក្នុងស្ថានភាពបន្ទាន់តាមលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាពុំបានដឹងអំពីអត្ថិភាពនៃមូលដ្ឋានទិន្នន័យនេះទេ។ ការណ៍នេះនឹងមានរៀបរាប់បន្ថែមក្នុងផ្នែក ខ ខាងក្រោម។

៥. សហព្រះរាជអាជ្ញាក៏សូមធ្វើការសន្និដ្ឋានផងដែរថា ការច្រានចោលណាមួយចំពោះសារទូរលេខនេះ នឹងបង្ករឲ្យមានភាពអយុត្តិធម៌។ ការពិតគឺថា សារទូរលេខទាំងនេះនឹងបញ្ជាក់បន្ថែមទៅលើភ័ស្តុតាងដទៃទៀតចំពោះបញ្ហាគន្លឹះនានា (ដូចជា ការជម្លៀសដោយបង្ខំមុនឆ្នាំ១៩៧៥ ការធ្វើទារុណកម្មចំពោះប្រជាជនស៊ីវិល និងការសម្លាប់ទាហាន និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ) គឺជាមូលហេតុដែលត្រូវទទួលយកភ័ស្តុតាងថ្មី សម្រាប់គោលបំណងនៃការបង្កើតការពិត ឲ្យហួសពីវិមតិសង្ស័យ។ ប៉ុន្តែលើសពីនេះទៀត សហព្រះរាជអាជ្ញាសន្និដ្ឋានថា ព័ត៌មានដែលមាននៅក្នុងសារទូរលេខ បូកបន្ថែមជាពិសេសទៅលើខ្លឹមសារនៃភ័ស្តុតាងដែលមានស្រាប់ តាមរយៈ i) ការរៀបរាប់ពីគួរយ៉ាងបន្ថែមអំពីការជម្លៀសដោយបង្ខំ និងការកាប់សម្លាប់ និង ii) ជួយបញ្ជាក់អំពីការពិតទាក់ទងនឹងទីកន្លែងរបស់ ខៀវ សំផន ក្នុងអំឡុងឆ្នាំ១៩៧៤ ដែលជាបញ្ហាមួយដែល

[6] *ក្នុងឯកសារដដែលដូចខាងលើ*។ សម្រាប់ករណីយុត្តិសាស្ត្រអន្តរជាតិ សូមមើល *រដ្ឋអាជ្ញា ទល់នឹង Stanislav Galić,* IT-98-29-A, សាលដីកាលើពាក្យសុំធ្វើឡើងដោយអយ្យការសុំការអនុញ្ញាតប្តឹងសាទុក្ខ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ១៤ ធ្នូ ២០០១ ត្រង់កថាខណ្ឌទី១៣។ *រដ្ឋអាជ្ញា ទល់នឹង Fulgence Kayishema, ICTR-01-67-Rllbis,* សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំការពិចារណាឡើងវិញ និងតាមជម្រើសផ្សេង សុំការបញ្ជាក់លើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំ (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ៣ កុម្ភៈ ២០១១ ត្រង់កថាខណ្ឌទី៣។ *រដ្ឋអាជ្ញា ទល់នឹង Stanislav Galić,* IT-98-29-A, សាលដីកាលើរបស់មេធាវីការពារក្តីសុំការពិចារណាឡើងវិញ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ១៦ កក្កដា ២០០៤ ត្រង់កថាខណ្ឌទី២។

មេធាវីការពារក្តីបានស្វែងរកនាពេលថ្មីៗនេះដើម្បីបញ្ចូលជាភស្តុតាងក្នុងការច្រានចោល សំផន ចេញពីការចូលរួមនៅក្នុងសេចក្តីសម្រេច អំពីការជម្លៀសដោយបង្ខំឲ្យចាកចេញពីទីប្រជុំជននានា បន្ទាប់ពីជ័យជំនះរបស់ខ្មែរក្រហម[7]។

៦. អំណះអំណាងទាំងនេះ ត្រូវបង្កើតបន្ថែមទៀតនៅក្នុងផ្នែក ខ និង ផ្នែក គ ខាងក្រោម។

## *ខ. យថាភូតភាព និងភាពជឿទុកចិត្តបានចំពោះសារទូរលេខ*

៧. បន្ទាប់ពីមានការបញ្ជាក់របស់អង្គជំនុំជម្រះថា ខ្លួនមិនអាចបញ្ជាក់បានពីមូលដ្ឋាននៃព័ត៌មានដែលបានផ្តល់ជូនតាមរយៈសំណើដើម ចំពោះសារទូរលេខទាំងនោះពិតជាមានយថាភូតពិតប្រាកដនោះ សហព្រះរាជអាជ្ញា ក៏បានចាត់ឲ្យមានការស្រាវជ្រាវយ៉ាងទូលំទូលាយមួយពីមូលដ្ឋានទិន្នន័យដែលអាចរកបានជាសាធារណៈនេះ ដើម្បីឲ្យដឹងថាតើ គេអាចបញ្ជាក់ពីយថាភូតឲ្យបានឆាប់រហ័សដែរឬទេ។ សារទូរលេខសហរដ្ឋអាមេរិកចំនួន២៦ ត្រូវបានរកឃើញ និងទាញយកពីគេហទំព័ររបស់បណ្ណសារជាតិ និងការគ្រប់គ្រងកំណត់ហេតុរបស់សហរដ្ឋអាមេរិក (the United States National Archives and Records Administration) (“NARA”) ដែលជាកន្លែងរក្សាទុកកំណត់ហេតុផ្លូវការរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក[8]។ សារទូរលេខ គឺជាផ្នែកនៃសំណុំឯកសារដ៏ធំមួយដែលគេលែងទុកជាសម្ងាត់បន្តទៀត និងត្រូវបានបញ្ចេញជាសាធារណៈដោយក្រសួងការបរទេសសហរដ្ឋអាមេរិក បន្ទាប់ពីមានការត្រួតពិនិត្យជាប្រព័ន្ធមួយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥។ ការពិតនេះច្បាស់ណាស់ថា បានបោះពុម្ពចេញពីជើងទំព័រ និងក្បាលទំព័រនៅលើទំព័រនិមួយៗនៃសារទូរ

---

[7] **E1/204.1** ប្រតិចារឹក, ស្វ សូជាតិ, ១០ មិថុនា ២០១៣, ត្រង់ម៉ោង 15.14.50 – 15.18.05។

[8] សម្រាប់ចិរវេលាមួយមិនកំណត់ NARA នៅរក្សា ១%-៣% នៃឯកសារនិងសម្ភារៈដែលបានបង្កើតឡើងក្នុងអំឡុងនៃការងាររបស់ខ្លួនដែលអនុវត្តដោយរដ្ឋាភិបាលសម្ព័ន្ធសហរដ្ឋអាមេរិក” អាស្រ័យដោយសារសារសំខាន់ខាងផ្លូវច្បាប់និងប្រវត្តិសាស្ត្រលេចធ្លោរបស់ឯកសារទាំងនេះ។ សូមមើល http://www.archives.gov/about/។ សហព្រះរាជអាជ្ញាអាចស្នើសុំសំណៅសារទូរលេខដែលមានការបញ្ជាក់ពីក្រសួងការបរទេសសហរដ្ឋអាមេរិក ប៉ុន្តែទទួលស្គាល់ថា ដំណើរការនេះអាចនឹងពន្យារពេលបន្ថែមទៀតចំពោះកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ ដូចអង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលច្រានចោលសារទូរលេខទាំងនេះ។

លេខដែលបានដាក់ជូននាពេលថ្មីៗនេះ[9]។ ព័ត៌មានដូចគ្នានេះក៏មានកំណត់សំគាល់លើសារទូរលេខដែលបានដាក់ជូនជាមួយនឹងសំណើដើមផងដែរ (នៅលើទំព័រដំបូងនៃសារទូរលេខនិមួយៗ នៅក្រោមចំណងជើងថា "សញ្ញាសំគាល់" ("The Markings")[10]។

៨. ភាពអាចរកបាន និងយថាភូតភាពនៃសារទូរលេខក្នុងទម្រង់ដើមរបស់វាដូចដែលបានបញ្ចេញដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក អាចផ្ទៀងផ្ទាត់បានដូចខាងក្រោម៖

ក. នៅលើគេហទំព័រផ្លូវការរបស់ NARA (http://aad.archives.gov/aad/), អ្នកប្រើអាចជ្រើសយកចេញពី "Time Spans."

ខ. នៅក្នុង Time Spans ឆ្នាំ១៩៦៥-១៩៧៥ (1965 - 1975 Time Span) គេអាចស្រាវជ្រាវមូលដ្ឋានទិន្នន័យមួយចំនួន។ មូលដ្ឋានទិន្នន័យជាក់លាក់ដែលមានសារទូរលេខទាំងនេះ គឺមានចំណងជើងថា "សំណុំឯកសារគោលនយោបាយការបរទេសកណ្ដាល, បង្កើត ៧/១/១៩៧៣ - ១២/៣១/១៩៧៦, ចងក្រងជាឯកសារក្នុងសម័យកាល ៧/១/១៩៧៣? - ១២/៣១/១៩៧៦ - *ក្រុមកំណត់ហេតុ ៥៩"* ("Central Foreign Policy Files, created 7/1/1973 - 12/31/1976, documenting the period 7/1/1973 ? - 12/31/1976 - *Record Group 59.")*

គ. សារទូរលេខជាក់លាក់ដែលបានដាក់ជូនដោយសហព្រះរាជអាជ្ញា បន្ទាប់មកគេអាចទាញយកបានតាមការស្រាវជ្រាវរក "Canonical ID" ដែលក្នុងនេះមានចុះបញ្ជីនៅលើគេហទំព័រដំបូងនូវសារទូរលេខនិមួយៗដូចបានដាក់ក្នុងឯកសារដើម។ នៅពេលណាទាញយកសារទូរលេខនោះហើយ ពាក្យ "Canonical ID" អាចឲ្យគេរកឃើញនៅក្នុងផ្នែកនៃ

[9] សូមមើលពាក្យខាងលើ និងខាងក្រោមនៃទំព័រនិមួយៗនៃសារទូរលេខដូចតទៅ៖ "Declassified/Released US Department of State EO Systematic Review 30 JUN 2005"។

[10] សូមមើល ជាឧទាហរណ៍ ឯកសារ **E282.1.1**, សារទូរលេខ ចុះថ្ងៃទី១៤ កញ្ញា ១៩៧៣ ត្រង់ ERN 00899034។

"Message Attributes" នៃអត្ថបទផ្លូវការនៃឯកសារ នៅក្រោមចំណងជើងថា "Document Number."[11]។

ដើម្បីងាយស្រួលធ្វើសេចក្តីយោង សហព្រះរាជអាជ្ញាសូមភ្ជាប់ទៅនឹងសំណើនេះនូវឧបសម្ព័ន្ធមួយ ដែលមានគេហទំព័រសម្រាប់ភ្ជាប់ពិតប្រាកដទៅនឹងគេហទំព័រ NARA សម្រាប់សារទូរលេខនិមួយៗ។

៩. សហព្រះរាជអាជ្ញាក៏យោង និងបង្រួមសេចក្តីរៀបរាប់របស់ខ្លួនក្នុងសំណើដើមដែរ អំពីទ្រង់ទ្រាយបន្ថែមនៃសារទូរលេខទាំងនោះ ដែលបញ្ជាក់អំពីយថាភូត និងភាពជឿទុកចិត្តបានរបស់វា[12]។ ដូចបានធ្វើការកត់សំគាល់នៅក្នុងសំណើនោះ សារទូរលេខដែលបាននឹងកំពុងដាក់ជូននាពេលនេះ គឺមានទម្រង់ដ៏សំខាន់ដូចគ្នាបះបិត ទៅនឹងសារទូរលេខរបស់សហរដ្ឋអាមេរិកដទៃទៀតដែលអង្គជំនុំជម្រះបានទទួលយករួចហើយថាមានយថាភូតពិតប្រាកដ និងអាចជឿទុកចិត្តបាន មានដូចជារបាយការណ៍ប្រចាំសប្តាហ៍ពីស្ថានទូតអាមេរិក (ជាទូទៅដាក់ចំណងជើងថា "របាយការណ៍ខ្មែរ") និងរបាយការណ៍ទៀងទាត់ ដែលបានផ្ញើដោយរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកដែលដាក់ចំណងជើង (ជាទូទៅដាក់ចំណងជើងថា "សេក្តីសង្ខេបសារព័ត៍មាន EA")[13]។ សហព្រះរាជអាជ្ញាកត់សំគាល់ផងដែរថា សារទូរលេខដែលជាកម្មវត្ថុនៃសំណើនេះ ដូចសារទូរលេខដែលបានទទួលយកកាលពីលើកមុនអញ្ចឹងដែរ គឺជាផ្នែកនៃសំណុំឯកសារដែលត្រូវបានចាត់ទុកថាលែងជាការសម្ងាត់/ដែលត្រូវបានបញ្ចេញជាសាធារណៈដោយក្រសួងការបរទេសសហរដ្ឋអាមេរិក បន្ទាប់ពីមានការត្រួតពិនិត្យជាប្រព័ន្ធ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ រួចមក។

[11] ជាឧទាហរណ៍ Canonical ID នៃសារទូរលេខ ចុះថ្ងៃទី១៤ កញ្ញា ១៩៧៣ (ដែលកាលពីមុនដាក់ថាឯកសារ **E282.1.1**) គឺជា "1973PHNOM09800_b"។ លេខនេះ បានចុះបញ្ជីនៅលើទំព័រទី៦ នៃឯកសារដូចគ្នា នៅពេលយើងទាញយកពីគេហទំព័រ NARA, ជាប់នឹងពាក្យ "លេខឯកសារ" "Document Number."។

[12] **E282** សំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨៧ (៤) នៃវិធានផ្ទៃក្នុង ស្តីពីសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ដែលទើបតែអាចរកបាននាពេលថ្មីៗនេះ, ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ត្រង់កថាខណ្ឌទី៥។

[13] ជាឧទាហរណ៍នៃសេចក្តីសង្ខេបសារព័ត៍មាន EA ដែលបានទទួលយករួចហើយដោយអង្គជំនុំជម្រះសាលាដំបូង គឺ **E3/3312** (D313/1.2.34), **E3/194** (D313/1.2.38), **E3/3551** (D366/7.1.727) និង **E3/3343** (D313/1.2.66)។

១០. ផ្អែកលើព័ត៌មានថ្មីៗដែលអាចរកបានដូចបានជំរាបជូនខាងលើនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សារទូរលេខទាំងនេះ ពេលនេះពិតជាបានបំពេញនូវលក្ខខណ្ឌសម្រាប់ការទទួលយក តាមវិធាន ៨៧(៣)(ខ) នៃវិធានផ្ទៃក្នុង មានន័យថា ជាព័ត៌មានដែលអាចរកបាន "នៅក្នុងពេលវេលាសមស្រប"។

១១. ត្រឡប់ទៅរកបញ្ហាអំពីភាពអាចរកបាននៃភ័ស្តុតាងនេះជាភាសាផ្សេងវិញ សហព្រះរាជអាជ្ញាកត់សំគាល់ថា ខ្លឹមសារសំខាន់ជាមធ្យម គឺប្រហែល ៤-៥ ទំព័រ ក្នុងមួយសារទូរលេខ (ផ្នែកដែលនៅសល់ គឺអាស័យដ្ឋាន សញ្ញាសំគាល់របស់ក្រសួងការបរទេសអាមេរិក ។ល។)។ ហេតុដូច្នេះ ប្រវែងភ័ស្តុតាងសរុប គឺស្ថិតក្នុងចន្លោះ១០០ទំព័រ ដែលចំនួននេះគឺតិចជាងប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការមួយនៅចំពោះមុខតុលាការនេះទៅទៀត។ មានសារទូរលេខពីរ ត្រូវបានបកប្រែទៅជាភាសាខ្មែររួចហើយ[14]។ សហព្រះរាជអាជ្ញាបានត្រៀមរួចជាស្រេចដើម្បីសម្របសម្រួលជាមួយអង្គភាពបកប្រែ ITU ដើម្បីធានាឲ្យប្រាកដថា ការបកប្រែសារទូរលេខដែលនៅសល់ទៅជាភាសាខ្មែរ និងបារាំង នឹងធ្វើឡើងបានទាន់ពេលវេលា។

## *គ. សារទូរលេខមានភ័ស្តុតាងថ្មីសំខាន់ចំពោះអង្គហេតុគន្លឹះនានា*

១២. វិធាន៨៧(៣)(ក) ផ្តល់ឲ្យអង្គជំនុំជម្រះសាលាដំបូង នូវឆន្ទានុសិទ្ធិដើម្បីច្រានចោលភ័ស្តុតាងដែលបានស្នើឲ្យទទួលយក ពេលណាខ្លួនរកឃើញថា ភ័ស្តុតាងនោះ "មិនពាក់ព័ន្ធ និងច្រំដែល"។ សហព្រះរាជអាជ្ញាកត់សំគាល់ថា អង្គជំនុំជម្រះមានកង្វល់ថា ព័ត៌មាននៅក្នុងសារទូរលេខមានលក្ខណៈច្រំដែលចំពោះភ័ស្តុតាងស្តីពីសារតាដែលមាននៅក្នុងសំណុំរឿងរួចហើយពាក់ព័ន្ធនឹង "កាលៈទេសៈដែលកើតមុននៅកម្ពុជាក្នុងចន្លោះឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៥"[15]។

១៣. សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញចំពោះការសន្និដ្ឋាននេះ ស្របតាមព័ត៌មានថ្មីៗដូចបានផ្តល់ជូនខាងក្រោម។ សារទូរលេខផ្តល់ភ័ស្តុតាងបន្ថែម (មិនដូចគ្នា ឬច្រំដែល)

---

[14] ទាំងនេះគឺឯកសារ **E282.1.1** និង **E282.1.2**។

[15] សេចក្តីសម្រេចច្រានចោល ត្រង់កថាខណ្ឌទី៨។

ពាក់ព័ន្ធនឹងបញ្ហាសំខាន់យ៉ាងខ្លាំងនៅក្នុងរឿងក្តីនេះ ដូចជា៖ i) ចលនារបស់ ខៀវ សំផន ក្នុងខែមិថុនា ឆ្នាំ១៩៧៤។ ii) ការរួមចំណែករបស់ ខៀវ សំផន នៅក្នុងបុព្វហេតុខ្មែរក្រហម និងកិច្ចខិតខំប្រឹងប្រែងក្នុងសង្គ្រាម។ iii) ការជម្លៀសដោយបង្ខំ និងការធ្វើបាបដោយអមនុស្សធម៌លើប្រជាជនស៊ីវិលដោយខ្មែរក្រហម ក្នុងតំបន់នានាហួសពីតំបន់ដែលបានគ្រប់ដណ្តប់រួចហើយ។ iv) តួរយ៉ាងបន្ថែមអំពីការសម្លាប់ និងការបាត់ខ្លួននៃសមាជិករបស់របបខ្មែរក្រហម ព្រមទាំងជនដទៃទៀតដែលគេសន្មតថាខ្មាំង ក្នុងតំបន់ដែលបានត្រួតត្រាដោយខ្មែរក្រហម។ ខាងក្រោម គឺជាឧទាហរណ៍មួយចំនួន អំពីប្រភេទនៃព័ត៌មានដែលមិនមានលក្ខណៈច្រំដែលឡើយ ប៉ុន្តែជាព័ត៌មានថ្មី និង/ឬព័ត៌មានបន្ថែមពីលើព័ត៌មានដែលមានស្រាប់ហើយ។

ក. សារទូរលេខមួយចំនួនផ្តល់នូវព័ត៌មានបន្ថែមអំពីចលនារបស់ ខៀវ សំផន និង អៀង សារី នៅខែមេសា ឧសភា និង មិថុនា ឆ្នាំ១៩៧៤ ដោយពួកគេទាំងពីរបានត្រឡប់មកក្នុងប្រទេសកម្ពុជាវិញនៅខែមិថុនា ដែលនៅពេលនោះ គណៈកម្មាធិការមជ្ឈិមបានធ្វើសេចក្តីសម្រេចជម្លៀសទីក្រុងនានាបន្ទាប់ពីបាន ជោគជ័យ[16]។ សារទូរលេខទាំងនេះរៀបរាប់ពីចលនារបស់ ខៀវ សំផន <u>បន្ទាប់ពីរយៈពេល</u> ដែលបានគ្រប់ដណ្តប់ដោយការបោះពុម្ពផ្សាយរបស់រណសិរ្សរួបរួមជាតិកម្ពុជាដែលមានស្រាប់ ក្នុងសំណុំរឿងនេះ[17] ហើយដូច្នេះវាបន្ថែមទៅនឹងភស្តុតាងដែលមានស្រាប់។

ខ. ព័ត៌មានបន្ថែមទាក់ទងនឹងសេចក្តីថ្លែងការណ៍ដែលបានធ្វើដោយ ខៀវ សំផន ដែលគាំទ្រដល់កិច្ចប្រឹងប្រែងសង្គ្រាម និងអំពាវនាវឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម - រួមមាន៖ ១) សេចក្តីថ្លែងការណ៍ ថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៤ អំពាវនាវឲ្យប្រជាជន "វាយឆ្មក់ឃ្លាំងអង្ករ" និង "បាញ់មន្ត្រី ផ្លូវការរបស់

---

[16] សារទូរលេខ ចុះថ្ងៃទី ២១ ឧសភា ១៩៧៤, ២៨ ឧសភា ១៩៧៤, ៤ មិថុនា ១៩៧៤, ១៩ មិថុនា ១៩៧៤, ២ កក្កដា ១៩៧៤, ៩ កក្កដា ១៩៧៤។

[17] សូមអាន ការបោះពុម្ពផ្សាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា (FUNK) ដែលមានចំណងជើងថា "ដំណឹងពីប្រទេសកម្ពុជា" - **E3/1238** (២ មេសា ១៩៧៤), **E3/1242** (៣ មេសា ១៩៧៤), **E3/113** (៤ មេសា ១៩៧៤), **E3/1254** (៦ មេសា ១៩៧៤), **E3/114** (៧ មេសា ១៩៧៤), **E3/1255** (១០ មេសា ១៩៧៤), **E3/167** (១១ មេសា ១៩៧៤), **E3/115** (២៣ មេសា ១៩៧៤) និង **E3/792** (២៤ មេសា ១៩៧៤)។

សាធារណៈរដ្ឋខ្មែរ”[18] និង ២) សេចក្ដីថ្លែងការណ៍ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៤ អំពាវនាវឲ្យកងទ័ពខ្មែរក្រហមបើក “ការវាយលុកយ៉ាងស្វាហាប់ និងខ្លាំងក្លា ... នៅលើគ្រប់សមរភូមិយុទ្ធសាស្ត្រទាំងបី” រួមមាន ទីក្រុងភ្នំពេញ និងទីរួមខេត្តនានា[19]។ ការវាយប្រហារនេះ ដែលបានចាប់ផ្ដើមនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ គឺជាការវាយលុកយ៉ាងខ្លាំងដែលបណ្ដាលឲ្យទីក្រុងភ្នំពេញ ត្រូវដួលរលំ[20]។

គ. ការកាប់សម្លាប់ដែលធ្វើឡើងដោយ ប.ក.ក មកលើប្រជាជនស៊ីវិលនៅក្នុងផ្នែកនានានៃប្រទេស ទាក់ទងនឹងភ័ស្តុតាងទាំងនោះដែលត្រូវបានទទួលយករហូតមកទល់ពេលនេះ គឺនៅមានកម្រិត ។ ឧទាហរណ៍ សារទូរលេខមួយរៀបរាប់អំពី “ការចេញទាំងហ្វូងធំៗ” នៃប្រជាជនចំនួន ២៧.៥០០នាក់ ដែលបានរត់គេចចេញពីតំបន់ដែលខ្មែរក្រហមបានកាន់កាប់ ហើយស្វែងរកជំរកក្នុងតំបន់នានាដែលបានគ្រប់គ្រងដោយរដ្ឋាភិបាលសាធារណៈរដ្ឋខ្មែរគឺ កំពង់ធំ សៀមរាប បាត់ដំបង និង ពោធិ៍សាត់[21]។ វាបាន រៀបរាប់បន្ថែមអំពីការផ្លាស់ប្ដូរលំនៅជាថ្មីដោយបង្ខំរបស់ ប្រជាជនស៊ីវិលឲ្យចូលទៅកាន់ “ដែនដីខាងក្នុង” ការត្រួតត្រាដ៏ឃោរឃៅទៅលើ ប្រជាជនស៊ីវិល ការបាត់ខ្លួនដែលបានបង្ខំ និង ការលុបបំបាត់ការប្រតិបត្តិសាសនា[22]។ ព័ត៌មាននេះ គឺជាការបញ្ជាក់ និងពិតជាការសំខាន់ ពីព្រោះវារៀបរាប់បន្ថែមទៀតអំពីគំរូនៃការប្រព្រឹត្តឡើង ដោយកង

---

[18] សារទូរលេខ ចុះថ្ងៃទី ៨ តុលា ១៩៧៤, ដែលមានចំណងជើងថា “របាយការណ៍ពីប្រទេសខ្មែរ (Khmer Report) – ៨ តុលា ១៩៧៤” ត្រង់កថាខណ្ឌទី៧។

[19] សារទូរលេខ ចុះថ្ងៃទី ៧ មករា ១៩៧៥, ដែលមានចំណងជើងថា “របាយការណ៍ពីប្រទេសខ្មែរ (Khmer Report) – ៧ មករា ១៩៧៥” ត្រង់កថាខណ្ឌទី៩។

[20] **E3/30** សេវាផ្សាយព័ត៌មានបរទេស - សូមមើលអត្ថបទ៖ “កងកម្លាំងក្រុងភ្នំពេញត្រូវបានដាក់ឲ្យប្រុងជើងការ”, ២ មករា ១៩៧៥ ត្រង់ ERN 00166658; “ខ្មែរក្រហមចាប់ផ្ដើមវាយលុកឆ្នាំថ្មី” ត្រង់ ERN 00166658, “ប្រជាជនកម្ពុជាត្រូវបានទទូចឲ្យរួបរួមគ្នានៅក្នុងវាយលុកឆ្នាំថ្មី” ត្រង់ ERN 00166659។ **E3/9** Philip Short, *ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ*, ត្រង់លេខ ERN 00396470។ **E3/1815** ប៊ិន ឃៀនិន, តើ ប៉ុល ពត ចូលកាន់អំណាចបែបណា? ត្រង់លេខ ERN 00487532។

[21] សារទូរលេខ ចុះថ្ងៃទី ២៧ កុម្ភៈ ១៩៧៤, ដែលមានចំណងជើងថា “ការហូរចូលទៅក្នុងខេត្តនៃជនភៀសខ្លួន (Influx of Refugees in Provinces)”, សេចក្ដីសង្ខេប និង កថាខណ្ឌទី ១ និង ៥។

[22] ដដែលដូចនឹងខាងលើ ត្រង់កថាខណ្ឌទី ២ និង ៥។

កម្លាំងរបស់ ប.ក.ក ទៅតាមគោលនយោបាយនានា ដែលសហព្រះរាជអាជ្ញាបានចោទ ប្រកាន់ថាបានកើតឡើងនៅមុនពេលទីក្រុងភ្នំពេញដួលរលំ។

ឃ. បន្ថែមពីការរត់គេចចេញរបស់ប្រជាជនស៊ីវិលពីខ្មែរក្រហមនោះ រួមមានពីតំបន់នានា នៅជុំវិញកំពត កំពង់ឆ្នាំង ស្វាយរៀង បាត់ដំបង និង ភ្នំពេញ (ព្រែកភ្នៅ អង្គស្នួល និង អារិយក្សត្រ)[23] ក៏ដូចជាការដែល ប.ក.ក បានចាប់ និងសម្លាប់ជនភៀសខ្លួន ដោយចោទថាជា "អ្នកធ្វើចារកិច្ច" នៅតាកែវ[24] និងនៅជុំវិញភ្នំពេញ[25]។ ជាថ្មីម្តងទៀត ទាំងអស់នេះគឺព័ត៌មានឭបន្ថែមនៃការប្រព្រឹត្ត របស់កងកម្លាំង ប.ក.ក ដែលគាំទ្រដល់ការបញ្ជាក់ការពិត ទាក់ទងនឹងអត្ថិភាពនៃគោលនយោបាយមជ្ឈិម។ ដូច្នេះភ័ស្តុតាងនេះមិនច្រំដែលទៅនឹងឯកសារដែលមានស្រាប់ហើយនោះទេ។

ង. សារទូរលេខក៏បានបន្ថែមព័ត៌មានថ្មីៗផងដែរ ទាក់ទងនឹងការសម្លាប់ជាប្រព័ន្ធទៅលើពួកទាហាន និងមន្ត្រីផ្លូវការរបស់សាធារណរដ្ឋខ្មែរ នៅមុនពេលទីក្រុងភ្នំពេញដួលរលំ។ ការណ៍នេះមានរួម ភ័ស្តុតាងនៃអំពើឃោរឃៅរបស់ខ្មែរក្រហមដែលបានរកឃើញនៅខែកក្កដា ឆ្នាំ១៩៧៤ បន្ទាប់ពីការកាន់កាប់ឧត្តុង្គ ដូចជា "គ្រោងឆ្អឹងចោលរាយប៉ាយដែលគេកាត់ក្បាល ឬ លលាដ៍ក្បាលដែលគេបានវាយ"[26]។ ព័ត៌មាននេះបង្គ្រប់ និងបន្ថែមទៅលើភ័ស្តុតាងដែលអង្គជំនុំជម្រះបានស្តាប់ ទាក់ទង នឹងការជម្លៀសឧត្តុង្គដោយបង្ខំ និងការសម្លាប់ពួកមន្ត្រីផ្លូវការសាធារណរដ្ឋខ្មែរនៅ

---

[23] សារទូរលេខ ចុះថ្ងៃទី ២ មីនា ១៩៧៤, ដែលមានចំណងជើងថា "ស្ថានការយោធាស្លាប់រស់នៅកំពត", កថាខណ្ឌទី ៣។ សារទូរលេខ ចុះថ្ងៃទី ២៣ ឧសភា ១៩៧៤, ដែលមានចំណងជើងថា "បច្ចុប្បន្នភាពប្រចាំខែស្តីពីជនភៀសខ្លួន – មេសា ១៩៧៤", កថាខណ្ឌទី ១។ សារទូរលេខ ចុះថ្ងៃទី ១៥ សីហា ១៩៧៤, ដែលមានចំណងជើងថា "បច្ចុប្បន្នភាពបរិយាយអំពីជនភៀសខ្លួន – កក្កដា ១៩៧៤"។ ឯកសារលេខ ២០-២៤, កថាខណ្ឌទី ២។ សារទូរលេខ ចុះថ្ងៃទី ៣ មករា ១៩៧៥, ដែលមានចំណងជើងថា "ស្ថានភាពជនភៀសខ្លួនជាបន្តបន្ទាប់ក្រោយការវាយប្រហារថ្មីៗរបស់កុម្មុយនីស្តខ្មែរ", កថាខណ្ឌទី ១។

[24] សារទូរលេខ ចុះថ្ងៃទី ១៥ សីហា ១៩៧៤, ដែលមានចំណងជើងថា "បច្ចុប្បន្នភាពបរិយាយអំពីជនភៀសខ្លួន – កក្កដា ១៩៧៤", កថាខណ្ឌទី ២។

[25] សារទូរលេខ ចុះថ្ងៃទី ៣ មករា ១៩៧៥, ដែលមានចំណងជើងថា "ស្ថានភាពជនភៀសខ្លួនជាបន្តបន្ទាប់ក្រោយការវាយប្រហារថ្មីៗរបស់កុម្មុយនីស្តខ្មែរ", កថាខណ្ឌទី ១។

[26] សារទូរលេខ ចុះថ្ងៃទី ១៣ កក្កដា ១៩៧៤, ដែលមានចំណងជើងថា "July 12 EA Press Summary", កថាខណ្ឌទី ៣។

ឧត្តុង្គនេះ[27]។ ដោយសារភាពសំខាន់នៃការជម្លៀសឧត្តុង្គជាការផ្តល់ដំណឹងជាមុនមួយ នៅមុនព្រឹត្តិការណ៍នានា ដែលបានកើតឡើងនៅទីក្រុងភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ព័ត៌មានថ្មី និងបន្ថែមនេះ ឆ្លើយតបនឹងបញ្ហាសំខាន់មួយក្នុងចំណោមបញ្ហាសំខាន់នានានៃរឿងក្តីនេះ - គឺអត្ថិភាពនៃគោលនយោបាយរបស់ ប.ក.ក ស្តីពីការជម្លៀសដោយបង្ខំ និងការសម្លាប់ពួកមន្ត្រីសាធារណរដ្ឋខ្មែរ នៅក្នុងរយៈពេលភ្លាមៗនៅមុនព្រឹត្តិការណ៍នានានៃសំណុំរឿង ០០២/០១។ ព័ត៌មាននេះ ក៏មានការទាក់ទងយ៉ាងជាក់លាក់ផងដែរទៅនឹងបញ្ហាស្តីពីការដឹងឮរបស់ ខៀវ សំផន និងការគាំទ្រចំពោះឧក្រិដ្ឋកម្មរបស់ ប.ក.ក - នៅក្នុងសេចក្តីថ្លែងការណ៍មួយដែលបានធ្វើឡើងកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៤ ខៀវ សំផន បានយោងទៅដល់ជ័យជំនះរបស់ខ្មែរក្រហមនៅឧត្តុង្គ ដោយបានអួតក្អេងក្អាងថា "នៅថ្ងៃទី១៨ ខែមីនា កងកម្លាំងរំដោះជាតិខ្មែររបស់ ប្រជាជនយើងបានរំដោះឧត្តុង្គ ដោយបានធ្វើឱ្យពួកទាហានអាយ៉ង និងទាហានគាំទ្រពួកវានៅ ទីនោះត្រូវសាបសូន្យ។ ម្យ៉ាងទៀត ពួកខ្មាំងជាង ៥.០០០នាក់ត្រូវបានកំទេចចោល, ១.៥០០នាក់ ត្រូវបានចាប់ខ្លួន" (សង្កត់ន័យបន្ថែមដោយ គូសបន្ទាត់ពីក្រោម)។

ច. សារទូរលេខក៏បានអះអាងផងដែរ អំពីភ័ស្តុតាងសំខាន់ប្លែកថ្មីៗ ឬបន្ថែម ដែលជាពន្លឺឆ្លើយតបទៅ នឹងការអះអាងរបស់មេធាវីការពារក្តី អំពីការសន្មតថាមានក្តីបារម្ភជាមនុស្សធម៌ពីប្រជាជនស៊ីវិល ដែលការបារម្ភនេះត្រូវបានចោទប្រកាន់ថា ជាការចង្អុលភ័ស្តុតាងពីការសម្រេចចិត្តជម្លៀសទីក្រុងភ្នំពេញ។ សារទូរលេខមួយដែលបានសរសេរ តែពីរខែប៉ុណ្ណោះ មុនរបាយការណ៍ស្តីពីទីក្រុងភ្នំពេញដួលរលំ អំពីគំរូដដែលៗនៃការវាយប្រហាររបស់ ប.ក.ក ទៅលើភូមិនានា និងការដុតបំផ្លាញដោយមានកងកម្លាំង ប.ក.ក ប្រមូលផ្តុំការបាញ់ប្រហាររបស់ខ្លួនទៅលើពួក "អ្នកភូមិជាជំនួសឱ្យពួក ទាហាន"[28]។ របាយការណ៍កត់សម្គាល់ថា ការឃោសនារបស់ ប.ក.ក

[27] **E1/97.1** ប្រតិចារឹក, រ៉ោម ទុន (ភី ភួន), ២៦ កក្កដា ២០១២, ត្រង់ម៉ោង 09.45.02 - 09.48.52, 10.20.22 - 10.26.50, 11.01.32 - 11.05.36។ **E1/190.1** ប្រតិចារឹក, Philip Short, ៧ ឧសភា ២០១៣, ត្រង់ម៉ោង 13.34.38 - 13.38.54។

[28] សារទូរលេខ ចុះថ្ងៃទី ៨ កុម្ភៈ ១៩៧៥, ដែលមានចំណងជើងថា "បច្ចុប្បន្នភាព, របាយការណ៍ស្តីពីស្ថានភាពរបស់ជនភៀសខ្លួន", កថាខណ្ឌទី ១ និង ២។

ដោយបានប្រកាសថាពួកអ្នកភូមិ ដែលប្រកែកមិនព្រមសហការថាជា "ខ្មាំងសំខាន់" ដោយមានព្រះសង្ឃព្រះពុទ្ធសាសនា និងពួកកងកម្លាំងសាធារណៈរដ្ឋខ្មែរ ជាខ្មាំងប្រភេទ ទីពីរ និងទីបី។ ជាការសំខាន់ សារទូរលេខរាយការណ៍ ថា "នេះមិនមែនជាបាតុភូតដាច់ដោយឡែក ទេ (sic) ប៉ុន្តែវាទំនងជាការបញ្ជាក់ពីយុទ្ធសាស្ត្រថ្មីមួយរបស់ខ្មាំង ដើម្បីធ្វើឲ្យមានការឈឺជាប់កាន់តែខ្លាំងឡើងថែមទៀតទៅលើប្រជាជនស៊ីវិលកម្ពុជា"[29]។ សារៈសំខាន់នៃព័ត៌មានបន្ថែមថ្មីនេះ មិនគួរត្រូវបានប៉ាន់ប្រមាណដោយស្មើរៗនោះទេ។ ឯកសារដែលបញ្ជាក់ពីភាពឃោរឃៅយ៉ាងជាប់លាប់នៃការវាយប្រហាររបស់ ប.ក.ក ទៅលើទីក្រុង និងទីរួមខេត្តនានា រហូតមកទល់ខែមេសា ឆ្នាំ១៩៧៥ បានជួយបញ្ជាក់ការពិតទាក់ទងនឹងអំណះអំណាងរបស់មេធាវីការពារក្តី ស្តីពីចេតនាមនុស្សធម៌ទាក់ទងនឹងប្រជាជនស៊ីវិល និងជនភៀសខ្លួននៅគ្រប់តំបន់ដែលមិននៅក្រោមការត្រួតត្រារបស់ខ្លួន រួមទាំង ទីក្រុងភ្នំពេញផង។ ការណ៍នេះ ដោយឡែកគឺយ៉ាងដូច្នេះ ដោយសារថាគោលនយោបាយរបស់ ប.ក.ក ត្រូវបានគេលើកឡើងចោទប្រកាន់ថា ត្រូវបានដាក់ឲ្យអនុវត្តយ៉ាង ជាប់លាប់នៅពាសពេញទឹកដីនៃប្រទេសកម្ពុជា ទាំងនៅមុន និងក្រោយ ខែមេសា ឆ្នាំ១៩៧៥។

ឆ. សារទូរលេខក៏បានបន្ថែមព័ត៌មានថ្មីៗផងដែរ ទាក់ទងនឹងការបន្តសម្លាប់ជាប្រព័ន្ធទៅលើពួកនាយទាហាន និងមន្ត្រីផ្លូវរបស់សាធារណរដ្ឋខ្មែរ នៅក្រោយពេលទីក្រុងភ្នំពេញដួលរលំ។ សារទូរលេខមួយនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៥ រាយការណ៍ពីការវិលត្រឡប់របស់នាយទាហាន និងនាយទាហានរង FANK ចំនួន ៨៧ នាក់[30] ចូលមកប្រទេសកម្ពុជាវិញ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៥ និងការប្រហារជីវិតពួកគេនៅពេលក្រោយមក ដោយកងកម្លាំង ប.ក.ក[31]។ វាក៏បានរាយការណ៍ផងដែរពីការសម្លាប់រង្គាលលើពួកបុគ្គលិកទាហាន FANK ចំនួន ២៤៧នាក់ ដែលបានវិលត្រឡប់មកពីប្រទេសថៃ នៅក្បែរភូមិបឹងព្រីង[32]។ ព័ត៌មានទាំងអស់នេះបន្ថែមពីលើព័ត៌មាន

---

[29] ដដែលដូចនឹងខាងលើ ត្រង់កថាខណ្ឌទី ៣ និង ៤។

[30] FANK គឺជាពាក្យសរសេរកាត់នៃចំណងជើងជាភាសាបារាំងថា កងកម្លាំងសាធារណរដ្ឋខ្មែរ ។

[31] សារទូរលេខ ចុះថ្ងៃទី ៩ កញ្ញា ១៩៧៥, ដែលមានចំណងជើងថា "ការសម្លាប់បុគ្គលិកយោធាយ៉ាងរង្គាល ដែលគេធ្លាប់បានរាយការណ៍ពីមុន", កថាខណ្ឌទី ២។

[32] ដដែលដូចនឹងខាងលើ។

ស្តីពីការ សម្លាប់ដែលបានគ្រោងរៀបចំ ទៅលើពួកនាយទាហាន និងមន្ត្រីផ្លូវការរបស់សាធារណៈរដ្ឋខ្មែរ ដែលមានសារៈសំខាន់ដែលថាវាស្របពេលជាមួយគ្នានឹងការសម្លាប់នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានរៀបរាប់ក្នុងភ័ស្តុតាងជាសក្ខីកម្មដែលបានស្តាប់រួចហើយរហូតមកទល់ពេលនេះ។ ដូច្នេះ ពួកវាបានគាំទ្រដល់អត្ថិភាពនៃគោលនយោបាយមជ្ឈិម ដែលគេបានអនុវត្តនៅទូទាំងប្រទេស បន្ទាប់ពីការជម្លៀសទីប្រជុំជននានាតាមទីក្រុង នៅខែមេសា ឆ្នាំ១៩៧៥។

១៤. ដោយសារភាពស្មុគស្មាញនៃរឿងក្តីនេះ និងដោយសារវិសាលភាពនៃពេលវេលា និងភូមិសាស្ត្ររបស់វា សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា សូមឲ្យទទួលយកភ័ស្តុតាងដែលបង្គ្រប់ និងបន្ថែមទាំងនេះ ទៅលើភ័ស្តុតាងជាសក្ខីកម្ម និងជាឯកសារ ដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីជួយសម្រួលដល់ការស្វែងរកបញ្ជាក់ការពិត និងក្នុងន័យ ដើម្បីផលប្រយោជន៍នៃយុត្តិធម៌។ អង្គជំនុំជម្រះ បានស្វែងរកយ៉ាងត្រឹមត្រូវនូវការជំនុំជម្រះក្តីមួយដ៏ឆាប់រហ័ស។ នៅក្នុងបរិបទនេះ លទ្ធភាពដែលអាចលើកជាតួយ៉ាងនូវភ័ស្តុតាងជាសក្ខីកម្មស្តីពីការប្រព្រឹត្ត របស់ ប.ក.ក នៅពាសពេញប្រទេសកម្ពុជា នៅក្នុងរយៈពេលភ្លាមៗនៅមុនទីក្រុងភ្នំពេញដួលរលំនោះពិតជាលំបាក។ ភ័ស្តុតាងជាឯកសារដែលទុកចិត្តបាន ដូចជារបាយការណ៍វិភាគសហកាលដែលបាន សរសេរសម្រាប់ជាការប្រើប្រាស់ផ្ទៃក្នុងរដ្ឋាភិបាល គឺជាប្រភពដ៏សំខាន់មួយនៃព័ត៌មានដែលគួរឲ្យទុកចិត្ត ស្តីពីព្រឹត្តិការណ៍ទាំងនេះ។ ភ័ស្តុតាងដែលសហព្រះរាជអាជ្ញាបានដាក់ជូននេះ មិនច្រើនពេកនោះទេ ហើយគេអាចយល់បាន និងប្រើប្រាស់បាន ដោយពុំមានការពន្យារពេលនោះឡើយ។

១៥. សហព្រះរាជអាជ្ញារំលឹកថា៖ ១) ទាំងជនជាប់ចោទទាំងពីរបានប្រឆាំងនឹងការចោទប្រកាន់ដែលថាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺមិនស្របច្បាប់ ដោយបានអះអាងផ្ទុយពីនេះថា ការជម្លៀសនោះត្រូវបានជម្រុញដោយគោលបំណងមនុស្សធម៌ត្រឹមត្រូវតាមច្បាប់, ២) ជនជាប់ចោទទាំងពីរ បានប្រឆាំងនឹងការចោទប្រកាន់ដែលថា បកក មានគោលនយោបាយសម្លាប់ ពួកមន្ត្រីរបស់សាធារណរដ្ឋខ្មែរ និងពួកខ្មាំងដទៃទៀត នៅខែមេសា ឆ្នាំ១៩៧៥, និង ៣) ខៀវ សំផន បានបដិសេធសូម្បីតែការដឹងឮ ឬការចូលរួមចំណែកនៅក្នុងផែនការជម្លៀសទីក្រុង នៅក្រោយ

ជ័យជំនះខែមេសា ឆ្នាំ១៩៧៥ ក៏មិនដឹងដែរ។ នៅក្នុងកាលៈទេសៈទាំងនេះ ការទទួលយកភ័ស្តុតាងដែលគួរឲ្យទុកចិត្តបាន ដែលបង្ហាញដោយមានគោលនយោបាយរបស់ បកក ប្រកបទៅ ដោយភាពត្រឹមត្រូវខ្លាំងជាង និងអាកប្បកិរិយាភ្លាមៗនៅមុនខែមេសា ឆ្នាំ១៩៧៥ ក៏ដូចជា ចលនា និងសេចក្តីថ្លែងការណ៍នៅក្នុងរយៈពេលនោះរបស់ ខៀវ សំផន គឺដើម្បីជាប្រយោជន៍នៃយុត្តិធម៌។

## III. **សេចក្តីសន្និដ្ឋាន**

១៦. សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា៖

ក. សារទូរលេខ គឺត្រូវបានឆ្លើយថាភាព និងគួរឲ្យទុកចិត្តបាន។

ខ. ដោយសារ សារទូរលេខ សង្ខេបខ្លីៗ ហើយសារទូរលេខនេះអាចបកប្រែដោយពុំមានការពន្យារពេលឡើយ និង

គ. សារទូរលេខនេះមានលក្ខណៈពាក់ព័ន្ធ និងមានតម្លៃជាភវនីយភាពចំពោះបញ្ហាសំខាន់ៗនៅក្នុងរឿងក្តីនេះ និងមិនមានលក្ខណៈច្រំដែលទៅនឹងព័ត៌មានដែលមានស្រាប់ ប៉ុន្តែផ្ទុយទៅវិញ ត្រូវបន្ថែមចំពោះព័ត៌មាននោះ និងជួយដល់ការបញ្ជាក់ការពិត។

១៧. ទាក់ទងទៅនឹងកាលៈទេសៈថ្មីៗដែលបានកើតឡើង ចាប់តាំងពីការដាក់សំណើដំបូង សហព្រះរាជអាជ្ញាសន្និដ្ឋានថាលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចបដិសេធនេះ គឺបានតម្រូវហើយ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ អង្គជំនុំជម្រះត្រូវអនុញ្ញាតឲ្យមានការទទួលយកនូវសារទូរលេខទាំងនេះ និងស្នើឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចដូច្នេះ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** William SMITH សហព្រះរាជអាជ្ញារង | | [signature] |